ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ ០០៥/ទ.ស.ម ២០១៧

# សារលិខិតរំលែកទុក្ខ

**ជូន**

ចំពោះក្រុមគ្រួសារសព ព្រិន្ទបាលទោ **ស៊ាង នរិន្ទ** ជាទីស្រឡាញ់រាប់អាន !

ក្នុងនាមនាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទ ខ្ញុំមានសេចក្តីរន្ធត់ក្រៀមក្រំជាទីបំផុត ដោយព្រិន្ទបាលទោ ស៊ាង នរិន្ទ ជំនួយការត្រួតពិនិត្យគុណភាពនៃកងវិស្វកម្មសំណង់លេខ៤៥៩ ក្នុងបេសកកម្មពហុខ្ជាតរួមគ្នានៃសហប្រជាជាតិ ដើម្បីស្ថេរភាពនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល (MINUSCA) បានពលីជីវិត កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង២០:០០នាទី ដោយសារការពួនស្ទាក់វាយប្រហារពីក្រុមប្រដាប់អាវុធមួយក្រុម មកលើក្បួនយុទ្ធដំណើរកងកម្លាំងកម្ពុជា និងកងកម្លាំងប្រទេសម៉ារ៉ុក ។

ការបាត់បង់រូបព្រិន្ទបាលទោ ស៊ាង នរិន្ទ គឺជាការបាត់បង់យោធិនមួយរូប ដែលបានលះបង់កម្លាំងកាយចិត្ត ដើម្បីបម្រើជាតិមាតុភូមិ និងប្រជាជន ក្នុងការចូលរួមចំណែកដោយស្ម័គ្រចិត្តក្នុងបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ក្នុងនាមមនុស្សធម៌ ។

ក្នុងក្របខណ្ឌនៃការបំពេញបេសកកម្មខាងលើ ព្រិន្ទបាលទោ ស៊ាង នរិន្ទ បានយកចិត្តទុកដាក់អនុវត្តការងារយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមលើកកម្ពស់កេរ្តិ៍ឈ្មោះ កិត្តិយសជាតិមាតុភូមិ ពិសេស កងយោធពលខេមរភូមិន្ទលើឆាកអន្តរជាតិ ។

ក្នុងនាមខ្លួនខ្ញុំផ្ទាល់ នាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទ សូមចូលរួមរំលែកនូវសេចក្តីទុក្ខដ៏ក្រៀមក្រំក្តុកក្តួលអាឡោះអាល័យជាទីបំផុត ជាមួយក្រុមគ្រួសារ ញាតិមិត្តទាំងអស់នៃសព និងសូមបួងសួងដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមបីបាច់រក្សាដួងវិញ្ញាណក្ខន្ធព្រិន្ទបាលទោ ស៊ាង នរិន្ទ បានទៅសោយសុខក្នុងសុគតិភព ជានិច្ចនិរន្តរ៍តរៀងទៅ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមក្រុមគ្រួសារ និងញាតិមិត្តទាំងអស់នៃសព ទទួលនូវមនោសញ្ចេតនាចែករំលែកទុក្ខដោយក្តីក្រៀមក្រំបំផុត ពីយើងខ្ញុំទាំងអស់គ្នា ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍.ទៀ-បាញ់